ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍លក

ភូមិ : លក
ឃុំ : ឫស្សីស្រុកខាងលិច
ស្រុក : កំពង់ត្រាច
ខេត្ត : កំពត

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍លក
# រយៈពេល ៣ឆ្នាំ
# (២០១២ - ២០១៤)

| | | |
|---|---|---|
| សហគមន៍នេសាទ | : | លក |
| ភូមិ | : | លក |
| ឃុំ | : | ឫស្សីស្រុកខាងលិច |
| ស្រុក | : | កំពង់ត្រាច |
| ខេត្ត | : | កំពត |

# មាតិកា
# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍


**១-ស្ថានភាពទូទៅ**

**២-អំពីប្រជាសាស្ត្រ**

ក- ប្រជាពលរដ្ឋ

ខ-មុខរបរ

**៣-កន្លែងនេសាទសហគមន៍ និងធនធានដែលមាននៅក្នុងនេសាទសហគមន៍**

ក-ទីតាំង

ខ-ដែននេសាទ

គ-តំបន់ដែលមានលទ្ធភាពបង្កើតកន្លែងអភិរក្ស

ឃ-ធនធានជលផល

**៤-ការធ្វើនេសាទ**

ក-អ្នកនេសាទ

ខ-ឧបករណ៍នេសាទ

គ-ការប៉ាន់ប្រមាណផលចាប់បានប្រចាំឆ្នាំ

**៥-ផែនការគ្រប់គ្រងសហគមន៍នេសាទ**

ក-ទស្សនៈវិស័យ

ខ-គោលបំណង

គ-ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

គ១-ផែនការប្រើប្រាស់ឧបករណ៍នេសាទ

គ២-ផែនការកែលំអដែននេសាទ

គ៣-ផែនការរៀបចំកន្លែងអភិរក្ស

គ៤-ផែនការគ្រប់គ្រងព្រៃលិចទឹក

គ៥-ផែនការចុះល្បាតទប់ស្កាត់បទល្មើសនេសាទ

គ៦-ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍

ឃ-យុទ្ធសាស្ត្រ

-តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍រយៈពេល ៣ឆ្នាំ

-តារាងកម្មវិធីការងារ

-តារាងឧបសម្ព័ន្ធ

# ផែនការគ្រប់គ្រង
# កន្លែងនេសាទសហគមន៍

## ១-ស្ថានភាពទូទៅ

សហគមន៍នេសាទលក បានបង្កើតឡើងដោយមហាសន្និបាតកំណើតដំបូងនៅថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៤ និងបានធ្វើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ចុះថ្ងៃទី............ ខែ............. ឆ្នាំ២០........។

សហគមន៍នេសាទលក មានទីតាំងស្ថិតនៅក្នុងភូមិ លក ឃុំ ឬស្សីស្រុកខាងលិច ស្រុក កំពង់ត្រាច ខេត្ត កំពត ដែលមានសមាជិកសរុបចំនួន ៣៤៧នាក់ ស្រីចំនួន ១០០នាក់ និងមានគណៈកម្មការចំនួន ០៧នាក់ ស្រី ០២នាក់។ ក្នុងនោះចំនួនគ្រួសារសរុប មានចំនួន ៦៣៧គ្រួសារ។

កន្លងមកសហគមន៍នេសាទនេះបានដំណើរការសកម្មភាពសំខាន់ៗរបស់ខ្លួន រួមមាន៖

- ចុះល្បាតត្រួតពិនិត្យដែននេសាទសហគមន៍
- ប្រជុំពិភាក្សាកំណត់ព្រំប្រទល់ដែននេសាទសហគមន៍
- ចុះកំណត់ព្រំប្រទល់ដែននេសាទសហគមន៍
- ចុះកំណត់កន្លែងអភិរក្សត្រីមេពូជ
- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការសរសេររបាយការណ៍ សរសេរកំណត់ហេតុ កិច្ចការរដ្ឋបាល ភាពជាអ្នកដឹកនាំ ច្បាប់ស្តីពីជលផល ច្បាប់ភូមិបាល........
- ទស្សនៈកិច្ចសិក្សាស្តីពី ធនាគារក្តាមនៅប្រទេសថៃ
- ទស្សនៈកិច្ចសិក្សាពីផែនការគ្រប់គ្រងសហគមន៍នេសាទនៅពាមក្រសោប ខេត្តកោះកុង
- ចូលរួមប្រជុំជាមួយភូមិ ឃុំ ។

## ២-អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

### ក-ប្រជាសាស្ត្រ

- ចំនួនប្រជាពលរដ្ឋសរុបនៅក្នុងសហគមន៍មានចំនួន ៦៣៧គ្រួសារ ស្មើ ២៩៣៩នាក់ ស្រី ១៤៩៩នាក់ ក្នុងនោះជនជាតិខ្មែរ ១០០%
- ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមាន ១០ នាក់
- ចំនួនជនពិការក្នុងសហគមន៍នេសាទគ្មាន
- ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមាន ០៧នាក់ ស្រី ០២ នាក់
- ចំនួនកុមារកំព្រាក្នុងសហគមន៍នេសាទមាន ១៥នាក់ ស្រី ០៥នាក់
- ចំនួនអ្នកមានជំងឺរ៉ាំរ៉ៃក្នុងសហគមន៍នេសាទមាន ០៨នាក់ ស្រី ០២នាក់
- ប្រជាពលរដ្ឋក្នុងសហគមន៍នេសាទជាអ្នកកាន់សាសនាព្រះពុទ្ធ ១០០% ។
- ក្នុងចំណោមសមាជិកគ្រួសារ នៃសមាជិកសហគមន៍នេសាទទាំងអស់អ្នកមិនចេះអក្សរមានចំនួន ២០នាក់ ស្រី ១២នាក់ កំរិតថ្នាក់បឋមសិក្សាចំនួន ១០០ នាក់ ស្រី ៥០នាក់ មធ្យមសិក្សា ១៥០នាក់ ស្រី ៩០នាក់ និងកំរិតថ្នាក់ឧត្តមសិក្សាចំនួន ៣០នាក់ ស្រី ១៥នាក់ ។

**ខ-មុខរបរ**

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេះរួមមាន៖

- ធ្វើនេសាទ ចំនួន ៩៥ គ្រួសារ
- ធ្វើស្រែ ចំនួន ៥០០គ្រួសារ ទំហំ ២៥២,១៩ហិកតា
- ធ្វើវារីវប្បកម្ម គ្មាន
- ដាំបន្លែគ្មាន
- ធ្វើចំការចំនួន ១៥គ្រួសារ ទំហំ ០៨ហិកតា
- ចិញ្ចឹមសត្វ(មាន់ ទា ជ្រូក គោ ក្របី) ១៦៥ គ្រួសារ
- លក់ដូរចំនួន ៦៥ គ្រួសារ
- ជាងផ្ទះចំនួន ១០ គ្រួសារ
- ធ្វើសិប្បកម្មគ្មាន
- កែច្នៃផលនេសាទ (បង្គាក្រៀម ផ្អកចាវ មាំ បកសាច់ក្ដាម) ចំនួន ១០គ្រួសារ
- ដាំដំឡូងជ្វាចំនួន ២០០គ្រួសារ ទំហំ ២៥២,១៩ហិកតា
- កម្មករចល័តចំនួន ៦០នាក់ ស្រី ២០នាក់ ។

## ៣-កន្លែងនេសាទសហគមន៍ និងធនធានដែលមាននៅក្នុងកន្លែងនេសាទសហគមន៍

**ក-ទីតាំង**

កន្លែងនេសាទសហគមន៍លក មានទំហំ ៣៣០ហិកតា និងមានកំណត់និយាមកា ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង។

មានព្រំប្រទល់៖

- ខាងជើងទល់នឹងសហគមន៍នេសាទកោះគ្រឹស្នា
- ខាងត្បូងទល់នឹងភូមិថ្កូវ
- ខាងកើតទល់នឹងភូមិថ្កូវ និងភូមិត្រពាំងនៀល
- ខាងលិចទល់នឹងសមុទ្រ ។

**ខ-ដែននេសាទ**

កន្លែងនេសាទសហគមន៍លក មានបឹងចំនួន ០១ ព្រៃកចំនួន ០១និង មានត្រពាំងចំនួន ០២ ។

- បឹងព្រលិត ប្រវែង ១៥០០ម៉ែត្រx១០០ម៉ែត្រ នេសាទពីខែមីនា ដល់ ខែឧសភា
- ព្រែកលក ប្រវែង ១៥០០ម៉ែត្រx៣០ម៉ែត្រ នេសាទពេញ ១ឆ្នាំ
- ត្រពាំងម៉ាសៀង ប្រវែង ៣០ម៉ែត្រx៣០ម៉ែត្រ នេសាទពេញ ១ឆ្នាំ
- ត្រពាំងមាស ប្រវែង ៨០ម៉ែត្រx២៥ម៉ែត្រ នេសាទពេញ ១ឆ្នាំ
- ព្រៃលិចទឹក/ព្រៃកោងកាងទំហំសរុប ហិកតា ។

**គ-តំបន់ដែលមានលទ្ធភាពបង្កើតកន្លែងអភិរក្ស**

- តំបន់កោងកាងចាកចេញ ទំហំ ១០ហិកតា អភិរក្សជីវចម្រុះ និងកូនក្ដាមថ្ម ។

ឃ-ធនធានជលផល

- ប្រភេទត្រីសមុទ្រៈ ត្រីស ត្រីក្បាលហែង ត្រីក្តុកស ត្រីអាំងកើយ ត្រីបេកា ត្រីតុកកែ ត្រីចាប ត្រីអង្រៃ ត្រីកិ ត្រីឪឈាវ ត្រីកាពួច ត្រីចង្កោមបី ត្រីក្តចិន ត្រីក្បក ត្រីឆ្លាធូ ត្រីម្រេច ត្រីស្ពង ត្រីផ្ទោង ត្រីអណ្ដែងប៉ុយ ត្រីត្រសក់ ត្រីឆ្លាម ត្រីបបែល ត្រីកាវ៉ាវ ត្រីប្រម៉ា ត្រីកាម៉ុង ត្រីស្លឹកឬស្សី ត្រីកន្តាំង ត្រីកន្ទុយរឹង.....។ល។
- ប្រភេទត្រីទឹកសាបៈ ត្រីក្រាញ់ ត្រីផ្ទក់ ត្រីអណ្តែង ត្រីកំភ្លាញ..........
- ប្រភេទវារីសត្វៈ ក្តាមសាច់ បង្គា ក្តាមសេះ ក្តាមថ្ម ក្តាមជ័រ មឹក គ្រែងឈាម ងាវ ងាវភក់ ងាវស ខ្យងហូល បង្កង បង្កងប៉ាក អណ្តើក កន្ទាយ បល្ល័ងកាស កញ្ជ អន្ទង់ ខ្ទឹង គ្រំក្រឡាហូល ផ្សោតប៉ាវ៉ា ល្មិច បង្កប ពស់ថ្លាន់ ពស់ទឹក ពស់ខ្មៅ ពស់វែក.........។ល។
- ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិៈ កោងកាង ក្រញ៉ូបស ក្រញឹមក្រហម ស្មែ ប្រង់ អម្ពូ អម្ពា ខ្នាញក្របាញញី ក្របាញឈ្មោល តាប៊ុន មែសាក់ ផ្លង បើស ចាក ឈើជ័រ វល្លិក្បាលស្វា ត្រចៀកក្រាញ់ ស្មាច់ ..........។ល។

## ៤-ការធ្វើនេសាទ

ក-អ្នកនេសាទ

- អ្នកនេសាទជាសមាជិកសហគមន៍ចំនួន ១៥០ នាក់ ស្រី ៦០ នាក់
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទ នៅក្នុងសហគមន៍មានចំនួន ២២០ នាក់ ស្រី ៧០នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីខាងក្រៅសហគមន៍មានចំនួន ២១០ នាក់ ស្រី១១០នាក់

ខ-ឧបករណ៍នេសាទ

-ឧបករណ៍នេសាទ និងទូកកាណូតរបស់សមាជិកសហគមន៍នេសាទ

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|
| [illegible]ត្រីក្បក | ម៉ែត្រ | ០៥គ្រួសារ | ប្រវែង ៥០០ម៉ែត្រ ក្រឡាចាប់ពី ៣,៥សង្ទីម៉ែត្រ ឡើង | ពេញ ១ឆ្នាំ |
| លបក្តាម | លប | ១៥គ្រួសារ | ចំនួន ២០០លប ក្រឡាចាប់ពី ៦សង្ទីម៉ែត្រ ឡើង | ពេញ ១ឆ្នាំ |
| សំណាញ់ | គ្រឿង | ០៧គ្រួសារ | ចំនួន ១គ្រឿង បណ្តោយមិនលើសពី ៦ម៉ែត្រ | ពេញ ១ឆ្នាំ |
| លបទឹក | លប | ០៥គ្រួសារ | ចំនួន ៥០លប ក្រឡាចាប់ពី ៤សង្ទីម៉ែត្រ ឡើង | ពេញ ១ឆ្នាំ |
| [illegible] | ផ្លែ | ២០គ្រួសារ | | ពេញ ១ឆ្នាំ |
| [illegible] | ម៉ែត្រ | ១០គ្រួសារ | ចំនួន ៥០០ផ្លែ ប្រវែង ៥០០ម៉ែត្រ | ពេញ ១ឆ្នាំ |
| [illegible] | គ្រឿង | ០៥គ្រួសារ | ចំនួន ១គ្រឿង | ពេញ ១ឆ្នាំ |
| [illegible] | គ្រឿង | ២០គ្រួសារ | ចំនួន ១គ្រឿង | ពេញ ១ឆ្នាំ |
| [illegible] | នាក់ | ១៥នាក់ | ចំនួន ១គ្រឿង | ពេញ ១ឆ្នាំ |
| [illegible] | នាក់ | ១៧នាក់ | | ពេញ ១ឆ្នាំ |
| [illegible] | នាក់ | ១២នាក់ | ចំនួន ១គ្រឿង | ពេញ ១ឆ្នាំ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកចែវ | ០៥ | ១០០-២០០គីឡូក្រាម | |
| ទូកម៉ាស៊ីនលើ | ១៥ | ២០០-៥០០គីឡូក្រាម | ៧សេះ-១៣សេះ |

-ឧបករណ៍នេសាទ និងទូកកាណូតរបស់អ្នកនៅក្នុងតំបន់ប៉ុន្តែមិនមែនជាសមាជិកសហគមន៍នេសាទ

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|
| មងត្រីក្បក | ម៉ែត្រ | ៥០គ្រួសារ | ប្រវែង ៥០០ម៉ែត្រ ក្រឡាចាប់ពី ៣,៥សង្ទីម៉ែត្រ ឡើង | ពេញ ១ឆ្នាំ |
| សំណាញ់ | គ្រឿង | ៤០គ្រួសារ | ចំនួន ១គ្រឿង បណ្តោយមិនលើសពី ៦ម៉ែត្រ | ពេញ ១ឆ្នាំ |
| សន្ទូចរនង | ម៉ែត្រ | ៧០គ្រួសារ | ចំនួន ៥០០ផ្លែ ប្រវែង ៥០០ម៉ែត្រ | ពេញ ១ឆ្នាំ |
| លបក្តាម | លប | ៦០គ្រួសារ | ចំនួន ២០០លប ក្រឡាចាប់ពី ៦សង្ទីម៉ែត្រ ឡើង | ពេញ ១ឆ្នាំ |
| បង្កៃ | ផ្លែ | ៧៥គ្រួសារ | | ពេញ ១ឆ្នាំ |
| លបមឹក | លប | ៣៥គ្រួសារ | ចំនួន ៥០លប ក្រឡាចាប់ពី ៤សង្ទីម៉ែត្រ ឡើង | ពេញ ១ឆ្នាំ |
| ឈឺបរុញដៃ | គ្រឿង | ២៧នាក់ | ចំនួន ១គ្រឿង | ពេញ ១ឆ្នាំ |
| ឈ្នាង | គ្រឿង | ៨៥នាក់ | ចំនួន ១គ្រឿង | ពេញ ១ឆ្នាំ |
| អង្រុត | នាក់ | ៤៥នាក់ | ចំនួន ១គ្រឿង | ពេញ ១ឆ្នាំ |
| ភរបង្គា | នាក់ | ៣០នាក់ | | ពេញ ១ឆ្នាំ |
| ស្នចាក់បង្គា | នាក់ | ១៥នាក់ | ចំនួន ១គ្រឿង | ពេញ ១ឆ្នាំ |

| ប្រភេទទូក កាណូត | ចំនួនគ្រួសារ | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកចែវ | ៧០ | ១០០-២៥០គីឡូក្រាម | |
| ទូកម៉ាស៊ីនលើ | ២៦ | ៥០០-៨០០គីឡូក្រាម | ៦សេះ-១៣សេះ |
| ទូកម៉ាស៊ីនបាត | ៣៥ | ១០០០-៣០០០គីឡូក្រាម | ១៦សេះ-២៤សេះ |

-ឧបករណ៍នេសាទ និងទូកកាណូតរបស់អ្នក មិនមែនជាសមាជិកសហគមន៍ដែលមកពីខាងក្រៅសហគមន៍នេសាទ

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|
| មងត្រីក្បក | ម៉ែត្រ | ២០ទូក | ១ទូក=៣០០ម៉ែត្រ ក្រឡា ៤សង្ទីម៉ែត្រ | ពេញ ១ឆ្នាំ |
| សំណាញ់ | គ្រឿង | ៣០នាក់ | ១នាក់=០១គ្រឿង | ពេញ ១ឆ្នាំ |
| សន្ទូចរនង | ផ្លែ | ៤០ទូក | ១ទូក=៥០០ម៉ែត្រ | ពេញ ១ឆ្នាំ |
| លបក្តាម | លប | ១៨ទូក | ១ទូក=២០០លប | ពេញ ១ឆ្នាំ |
| សន្ទូចបង្កៃ | ផ្លែ | ១៨នាក់ | ១នាក់=០១គ្រឿង | ពេញ ១ឆ្នាំ |
| ឈឺបរុញដៃ | គ្រឿង | ១៥នាក់ | ១នាក់=០១គ្រឿង | ពេញ ១ឆ្នាំ |

| | | | | |
|---|---|---|---|---|
| ឈ្នាង | គ្រឿង | ៣០នាក់ | ១នាក់=០១គ្រឿង | ពេញ ១ឆ្នាំ |
| អង្រុត | គ្រឿង | ១៥នាក់ | ១នាក់=០១គ្រឿង | ពេញ ១ឆ្នាំ |
| រាវបង្គា | | ២០នាក់ | | ពេញ ១ឆ្នាំ |
| ស្នចាក់បង្គា | គ្រឿង | ១៥នាក់ | ១នាក់=០១គ្រឿង | ពេញ ១ឆ្នាំ |

| ប្រភេទទូក កាណូត | ចំនួនគ្រួសារ | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកម៉ាស៊ីនលើ | ៤០ | ៣០០-៨០០គីឡូក្រាម | ៧សេះ-១៣សេះ |

គ-ការប៉ាន់ប្រមាណផលចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ(គិតជាគីឡូក្រាម) | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រី | ១០០ | ២០០ | ៣០០ |
| ក្តាមសេះ | ២០០ | ៣០០ | ៥០០ |
| បង្គា | ១៥០ | ២៥០ | ៤០០ |

## ៥-ផែនការគ្រប់គ្រងសហគមន៍នេសាទ

ក-ទស្សនៈវិស័យ

សហគមន៍នេសាទលក មានទស្សនៈវិស័យរួមចំណែកគ្រប់គ្រងធនធានជលផលប្រកបដោយ សមធម៌ និង ចិរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

ខ-គោលបំណង

- ចូលរួមគ្រប់គ្រងដែននេសាទទឹកសាបដែលបានលុប ឬ កាត់បន្ថយពីឡូត៍នេសាទ កន្លែងនេសាទគ្រួសារដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ឬ សហគមន៍ធ្វើនេសាទ កន្លែងនេសាទបំរុង ទំនាបលិចទឹកក្នុងរដូវតំឡើង នាទីព្រៃលិចទឹក ។
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តភាព និងធានាការបែងចែកផលប្រយោជន៍ធនធានជលផល ជូនប្រជាពលរដ្ឋខ្មែរប្រកបដោយ សមធម៌
- ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍ តាមតយៈការអភិវឌ្ឍន៍ចំរុះដោយមានការចូលរួម
- ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ ហើយនឹងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់លើធនធានធម្មជាតិ ។

គ-ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

គ១-ផែនការប្រើប្រាស់ឧបករណ៍នេសាទ

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍គឺ រៀបចំឡើងដោយគិតគូរអំពី ប្រភេទឧបករណ៍នេសាទ ប្រភេទ ទំហំ ប្រវែង និងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ។

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | |
|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន |
| -ត្រពាំង<br>-បឹង | ពេញ១ឆ្នាំ | ឈ្នាង | | ១គ្រឿង |
| | | អង្រុត | | ១គ្រឿង |
| -ខោសក្តាម<br>-ខោសដីក្រហម<br>-ខោសកណ្តាល<br>-ខោសខ្ពស់<br>-ខោសទទឹង<br>-គ្រលងកាល | ពេញ១ឆ្នាំ | មងត្រីក្បក | ប្រវែង ៥០០ម៉ែត្រ ក្រឡាចាប់ពី ៣,៥សង្ទីម៉ែត្រ ឡើង | ៥០០ម៉ែត្រ |
| | | លបក្តាម | ចំនួន ២០០លប ក្រឡាចាប់ពី ៦សង្ទីម៉ែត្រ ឡើង | ២០០លប |
| | | សំណាញ់ | ចំនួន ១គ្រឿង បណ្តោយមិនលើសពី ៦ម៉ែត្រ | ១គ្រឿង |
| | | លបមឹក | ចំនួន ៥០លប ក្រឡាចាប់ពី ៤សង្ទីម៉ែត្រ ឡើង | ៥០លប |
| | | សន្ទូចបង្កៃ | | |
| | | សន្ទូចរនង | ចំនួន ៥០០ផ្លែ ប្រវែង ៥០០ម៉ែត្រ | ៥០០ផ្លែ |
| | | ឈើបរុញដៃ | | ១គ្រឿង |
| | | ឈ្នាង | | ១គ្រឿង |
| | | អង្រុត | | ១គ្រឿង |
| | | រាវបង្គា | | |
| | | ស្នចាក់បង្គា | | ១គ្រឿង |

គ២-ផែនការកែលំអរដែននេសាទ

ផែនការកែលំអដែននេសាទ ត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម:

| ឈ្មោះដែននេសាទ | ទំហំ(ហ.ត) | ទំហំដែលត្រូវកែលំអរ | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ព្រែកលក | ៣០ម៉ែត្រ×១៥០០ម៉ែត្រ | ៣០ម៉ែត្រ×១៥០០ម៉ែត្រ | ស្តារព្រែក | មករា | មីនា |
| ខោសរាប | ២,៥ហិកតា | ២,៥ហិកតា | ដាំកោងកាង | មីនា | មេសា |

គ៣-ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស

ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស ត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម:

| ឈ្មោះដែននេសាទ | ទំហំ | ប្រភេទនៃការអភិរក្ស | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| តំបន់កោងកាងតាកចេញ | ១០ហិកតា | ជីវចម្រុះ និងកូនក្តាមថ្ម | -ផ្សព្វផ្សាយ<br>-បោះបង្គោល<br>-ស្លាកសញ្ញា<br>-ប្រអប់សិប្បនិម្មិត<br>-យាមល្បាត | | |

### គ៤-ផែនការគ្រប់គ្រងព្រៃលិចទឹក

ផែនការគ្រប់គ្រងព្រៃលិចទឹក ត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម:

| ឈ្មោះ/ទីតាំង | ទំហំ | ប្រភេទកូនឈើដែលត្រូវ និងការពារ | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ព្រៃលិចទឹក | ហិកតា | កោងកាង | -ផ្សព្វផ្សាយ<br>-បោះបង្គោល<br>-ស្លាកសញ្ញា<br>-កាប់រំលោះ<br>-យាមល្បាត | | |

### គ៥-ផែនការចុះល្បាតទប់ស្កាត់បទល្មើសនេសាទ

ផែនការចុះល្បាតទប់ស្កាត់បទល្មើសនេសាទ ត្រូវបានរៀបចំឡើងដូចខាងក្រោម:

| សកម្មភាព | គោលបំណង | លទ្ធផលរំពឹងទុក |
|---|---|---|
| ទំនាក់ទំនងជាមួយស្ថាបន័ពាក់ព័ន្ធលើការគ្រប់គ្រងសហគមន៍នេសាទ | ដើម្បីឱ្យអាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ពន្ធ័មានការចូលរួមសហការ និងជួយជំរុញការអនុវត្តន៍ឱ្យបានសមស្របតាមផែនការគ្រោងទុករបស់សហគមន៍នេសាទ | អាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ពន្ធ័មានការគាំទ្រនិងចូលរួមរាល់សកម្មភាព ដែលបានអនុវត្តរបស់សហគមន៍នេសាទមានភាពទទួលខុសត្រូវស្របទៅតាមគោលការណ៍ណែនាំច្បាប់ |
| ផ្សព្វផ្សាយពីច្បាប់ជលផលថ្មីច្បាប់បទដ្ឋាននានាដែលពាក់ព័ន្ធនិងចំណេះដឹងបរិស្ថានដល់ប្រជាពលរដ្ឋ | សមាជិកសហគមន៍និងប្រជាពលរដ្ឋយល់ដឹងអំពី វិស័យជលផល និងបរិ-ស្ថានហើយចូលរួមទប់ស្កាត់បទល្មើសនេសាទ ដើម្បីថែរក្សា និងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព | សមាជិកសហគមន៍និងប្រជាពលរដ្ឋក្នុងនិងក្រៅសហគមន៍ចូលរួមការពារ ថែរក្សា និងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយសម-ធម៌ និងការបំផ្លាញធនធានធម្មជាតិត្រូវបានថយចុះ |
| ប្រជុំពិភាក្សាគណៈកម្មការសហគមន៍រៀបចំផែនការប្រចាំខែនិងត្រីមាស | ដើម្បីឆ្លុះបញ្ចាំងនិងកំណត់ផែនការដែលបានអនុវត្តពង្រឹងសម្ថភាពលើការអនុវត្ត និង រៀបចំផែនការបន្តសំដៅការអនុវត្តទទួលបានជោគជ័យ | គណៈកម្មការទទួលបាននូវបទពិសោធន៏និងចំណេះដឹងថ្មីៗលើការដោះស្រាយបញ្ហានិងមានការកែលំអកាន់តែប្រសើរឡើង |
| សហការជាមួយស្ថាប័នជំនាញ សមត្ថកិច្ច និងសហគមន៍ជិតខាងក្នុងការចុះបង្ក្រាបបទល្មើស ០៣ដង/១ខែ | ដើម្បីបង្កើនកិច្ចសហការរវាងសហគមន៍ និងអាជ្ញាធរនិងសម្ថកិច្ចពាក់ព័ន្ធក្នុងការបង្ក្រាបបទល្មើសនេសាទ | ការនេសាទខុសច្បាប់ត្រូវបានកាត់បន្ថយ និងត្រូវបានលុបបំបាត់នៅក្នុងសហគមន៍លក |

## គ-ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍

ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ ត្រូវបានរៀបចំឡើងដូចខាងក្រោម :

| ប្រភេទប្រាស់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំចាប់បញ្ចប់ | ចំណូលសរុប | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានពីសមាជិកសហគមន៍នេសាទ | -ផ្សព្វផ្សាយជ្រើសរើសសមាជិកថ្មី<br>-ដើរប្រមូលភាគទានតាមផ្ទះសមាជិក | ខែ០៨ ឆ្នាំ២០១២<br>ខែ០៨ ឆ្នាំ២០១៣ | ខែ០៨ ឆ្នាំ២០១៤<br>ខែ០៨ ឆ្នាំ២០១៤ | | |
| ភាគទានប្រចាំឆ្នាំ | -ផ្សព្វផ្សាយជូនដំណឹងមុនរយៈពេល១៥ថ្ងៃ<br>-ដើរប្រមូលភាគទានតាមផ្ទះសមាជិក | ពាក់កណ្តាល<br>ខែ១១ ឆ្នាំ២០១២<br>ខែ១២ ឆ្នាំ២០១៣ | ពាក់កណ្តាល<br>ខែ១១ ឆ្នាំ២០១៤<br>ខែ១២ ឆ្នាំ២០១៤ | | |

## ឃ-យុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំ ដូចខាងក្រោម :

- បង្កើតគណៈកម្មការសម្រាប់អនុវត្តតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការ រួមមាន: សមាជិក គណៈកម្មការសហកមន៍នេសាទ ចាស់ទុំដែលមានបទពិសោធន៍និងចំណេះដឹងល្អៗ ជាពិសេសបញ្ហានេសាទ
- ស្នើសុំជំនួញបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់ចំពោះផែនការណាដែលទាក់ទងនិងបច្ចេកទេសជលផលដូចជា ការធ្វើផែនការកន្លែងអភិរក្សមេពូជត្រី ការរៀបចំកន្លែងអភិរក្សព្រៃលិច ទឹក កន្លែងអភិរក្សជីវៈចម្រុះ ការស្តារព្រែក ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី ការរកថវិកាទ្រទ្រង់ជាដើម
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការនានា គម្រោង និងម្ចាស់ជំនួយដើម្បីទទួលបានការឧបត្ថម្ភគាំទ្រ និងថវិការសម្រាប់ដំណើរការអនុវត្តផែនការ
- រៀបចំផែនការអនុវត្តផែនការតាមដំណាក់កាលនិមួយៗដោយជាក់លាក់
- ទាក់ទងជាមួយរដ្ឋបាលជលផលដើម្បីសុំការគាំទ្រថវិការ និងជួយរកដៃគូសម្រាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ
- កៀងគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការណ៍ចំពោះអ្នកនេសាទមកពីខាងក្រៅសហគមន៍
- ពង្រឹងសមត្ថភាពបច្ចេកទេស និង គ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តផែនការ
- បញ្ចូលផែនការគ្រប់គ្រងសហគមន៍នេសាទទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់។

**តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍លក រយៈពេល ៣ឆ្នាំ (២០១២ ដល់ ២០១៤)**

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ(រៀល) | ប្រភពជំនួយ | ពេលចាប់ផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ១-ការប្រើប្រាស់ឧបករណ៍នេសាទ | ប្រជុំផ្សព្វផ្សាយអំពីផែនការប្រើប្រាស់ឧបករណ៍នេសាទសហគមន៍ភូមិកែប | -សមាជិកនិងប្រជាពលរដ្ឋចូលរួមអនុវត្តតាមផែនការប្រើប្រាស់ឧបករណ៍នេសាទសហគមន៍ភូមិកែប -ផលត្រីនៅក្នុងសហគមន៍មានការកើនឡើងប្រជាពលរដ្ឋអាចរកត្រីបានពេញ០១ឆ្នាំ | ១០០,០០០រៀល | រដ្ឋបាលជលផល | ២០១២ | ២០១៤ | |
| | បិទផ្សាយឯកសារផែនការប្រើប្រាស់ឧបករណ៍នេសាទសហគមន៍ | | ៥០,០០០រៀល | រដ្ឋបាលជលផល | ២០១២ | ២០១៤ | |
| | ចែកចាយឯកសារផែនការប្រើប្រាស់ឧបករណ៍តាមផ្ទះ | | ៥០,០០០រៀល | រដ្ឋបាលជលផល | ២០១២ | ២០១៤ | |
| | ផ្សព្វផ្សាយតាមមេក្រូនូវផែនការប្រើប្រាស់ឧបករណ៍នេសាសហគមន៍ | | ៨០,០០០រៀល | រដ្ឋបាលជលផល | ២០១២ | ២០១៤ | |
| ២-ការកែលំអរដែននេសាទ | ដាំកូនកោងកាង | សំបូរកោងកាងផលនេសានៅក្នុងសហគមន៍មានការកើនឡើង | ៣០០,០០០រៀល | រដ្ឋបាលជលផល | ២០១២ | ២០១៤ | |
| | ស្តារព្រែក | ធ្វើឱ្យព្រែកមានជម្រៅជ្រៅ | ៤,០០០,០០០រៀល | រដ្ឋបាលជលផល | ២០១២ | ២០១៤ | |
| ៣-ការរៀបចំកន្លែងអភិរក្ស | ផ្សព្វផ្សាយពីកន្លែងអភិរក្សនិងការហាមឃាត់ដល់ប្រជាពលរដ្ឋឱ្យបានទូលំទូលាយ | សមាជិកសហគមន៍នេសាទនិងប្រជាពលរដ្ឋក្នុង និងក្រៅសហគមន៍ចូលរួមថែរក្សា និង | ៥០,០០០រៀល | រដ្ឋបាលជលផល | ២០១២ | ២០១៤ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | ការពារ | | | | | |
| | ចុះកំណត់ព្រំប្រទល់កន្លែងអភិរក្ស | តំបន់អភិរក្សមានព្រំប្រទល់ច្បាស់លាស់ | ៤,០០០,០០០រៀល | រដ្ឋបាលជលផល | ២០១២ | ២០១៤ | |
| | ធ្វើស្លាកសញ្ញាហាមឃាត់ចំនួន ២ផ្ទាំង | សមាជិកសហគមន៍នេសាទ និងប្រជាពលរដ្ឋក្នុង និងក្រៅសហគមន៍ចូលរួមការពារថែរក្សា | ៤០០,០០០រៀល | រដ្ឋបាលជលផល | ២០១២ | ២០១៤ | |
| | ល្បាតជាប្រចាំកន្លែងអភិរក្ស | សមាជិកក្រុមល្បាតចូលរួមល្បាតតាមផែនការ ៣ដង/ខែ | ២០,០០០រៀល | រដ្ឋបាលជលផល | ២០១២ | ២០១៤ | |
| ៤-ការគ្រប់គ្រងព្រៃលិចទឹក/កោងកាង | ប្រជុំរៀបចំផែនការគ្រប់គ្រងព្រៃលិចទឹក/កោងកាង | -ធនធានជលផលនឹងកើនឡើង<br>-ព្រៃលិចទឹកមាននិរន្តរភាព | ១០០,០០០រៀល | រដ្ឋបាលជលផល | ២០១២ | ២០១៤ | |
| | ផ្សព្វផ្សាយអំពី ផែនការប្រើប្រាស់ព្រៃកោងកាង | | ៥០០,០០០រៀល | រដ្ឋបាលជលផល | ២០១២ | ២០១៤ | |
| | ប្រមូលគ្រាប់កោងកាង | | ៨០,០០០រៀល | រដ្ឋបាលជលផល | ២០១២ | ២០១៤ | |
| | បណ្ដុះកូន ដាំ និងថែរក្សាការពារ | | ១០០,០០០រៀល | រដ្ឋបាលជលផល | ២០១២ | ២០១៤ | |
| | កាប់រំលោះប្រើប្រាស់ក្នុងគ្រួសារ | | | រដ្ឋបាលជលផល | ២០១២ | ២០១៤ | |
| | ទំនាក់ទំនងជាមួយស្ថាបន័ពាក់ព័ន្ធលើការគ្រប់គ្រងសហគមន៍នេសាទ | អាជ្ញាធរនិងស្ថាប័នពាក់ព័ន្ធមានការគាំទ្រនិងចូលរួមរាល់សកម្មភាពអនុវត្ត និងការអនុវត្តមានភាពទទួលខុស | ២០០,០០០រៀល | រដ្ឋបាលជលផល | ២០១២ | ២០១៤ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | ត្រូវស្របទៅតាមគោលការណ៍ណែនាំនៃច្បាប់ | | | | | |
| ៥-ការចុះល្បាតទប់ស្កាត់បទល្មើសនេសាទ | ផ្សព្វផ្សាយពីច្បាប់ជលផលថ្មី ច្បាប់បទដ្ឋាននានាដែលពាក់ព័ន្ធនិងចំណេះដឹងបរិស្ថានដល់ប្រជាពលរដ្ឋ | សមាជិកសហគមន៍នេសាទ និងប្រជាពលរដ្ឋក្នុង និងក្រៅសហគមន៍ចូលរួមការពារ ថែរក្សានិងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយសមធម៌ និងការបំផ្លិចបំផ្លាញធនធានត្រូវបានថយចុះ | ៥០០,០០០រៀល | រដ្ឋបាលជលផល | ២០១២ | ២០១៤ | |
| | ប្រជុំពិភាក្សាគណៈកម្មការសហគមន៍រៀបចំផែនការប្រចាំខែ និងត្រីមាស | គណៈកម្មការទទួលបាននូវបទពិសោធន៍និងចំណេះដឹងថ្មីៗលើការដោះស្រាយបញ្ហា និងមានការកែលំអរកាន់តែប្រសើរឡើង | ១០០,០០០រៀល | រដ្ឋបាលជលផល | ២០១២ | ២០១៤ | |
| | សហការជាមួយស្ថាប័នជំនាញសមត្ថកិច្ច និងសហគមន៍ជិតខាងក្នុងការចុះបង្ក្រាបបទល្មើស៣ដង/១ខែ | ការនេសាទខុសច្បាប់ត្រូវបានកាត់បន្ថយ និងត្រូវបានលុបបំបាត់នៅក្នុងសហគមន៍ភូមិកែប | ២០០,០០០រៀល | រដ្ឋបាលជលផល | ២០១២ | ២០១៤ | |
| ៦-ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ | ភាគទានពីសមាជិកសហគមន៍ | -ផ្សព្វផ្សាយជ្រើសរើសសមាជិកថ្មី ៣០នាក់/ឆ្នាំ<br>-ដើរប្រមូលភាគទានតាមផ្ទះសមាជិក | | សហគមន៍នេសាទ | ២០១២ | ២០១៤ | |
| | ភាគទានប្រចាំឆ្នាំ | សមាជិកសហគមន៍និងចូលរួមបង់ភាគទានប្រចាំឆ្នាំរៀងរាល់ឆ្នាំ | | សហគមន៍នេសាទ | ២០១២ | ២០១៤ | |

# តារាងកម្មវិធីការងារ

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១២ | | | | | | | | | | | | ២០១៣ | | | | | | | | | | | | ២០១៤ | | | | | | | | | | | |
| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| **១- ការប្រើប្រាស់ឧបករណ៍នេសាទ** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ១-១ ប្រជុំផ្សព្វផ្សាយអំពីផែនការប្រើប្រាស់ឧបករណ៍នេសាទ | | | | | ■ | | | | | | | | | | | | ■ | | | | | | | | | | | | ■ | | | | | | | |
| ១-២ បិទផ្សាយឯកសារផែនការប្រើប្រាស់ឧបករណ៍នេសាទ | | | | | ■ | | | | | | | | | | | | ■ | | | | | | | | | | | | ■ | | | | | | | |
| ១-៣ ចែកចាយឯកសារផែនការតាមផ្ទះ | | | | | | ■ | | | | | | | | | | | | ■ | | | | | | | | | | | | ■ | | | | | | |
| ១-៤ ផ្សព្វផ្សាយតាមមេក្រូពីផែនការប្រើប្រាស់ឧបករណ៍ | | | | | | ■ | | | | | | | | | | | | ■ | | | | | | | | | | | | ■ | | | | | | |
| **២-ការកែលំអរដែននេសាទ** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ២-១ ដាំកូនកោងកាង | | | | | | | | | | | | ■ | ■ | | | | | | | | | | | ■ | ■ | | | | | | | | | | | ■ |
| ២-២ ស្តារព្រែក | | | ■ | ■ | ■ | | | | | | | | | | ■ | ■ | ■ | | | | | | | | | | ■ | ■ | ■ | | | | | | | |
| **៣-ការរៀបចំកន្លែងអភិរក្ស** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៣-១ ផ្សព្វផ្សាយពីកន្លែងអភិរក្ស និងការហាមឃាត់ដល់ប្រជាពលរដ្ឋឱ្យបានទូលំទូលាយ | | | | ■ | ■ | | | | | | | | | | | ■ | ■ | | | | | | | | | | | ■ | ■ | | | | | | | |
| ៣-២ កំណត់ព្រំប្រទល់កន្លែងអភិរក្ស | | | | | | | | | | | | | ■ | | | | | | | | | | | | | | | | | | | | | | | |

| |
|---|
| ៣-៣ ធ្វើស្លាកសញ្ញាហាមឃាត់ |
| ៣-៤ ល្បាតជាប្រចាំកន្លែងអភិរក្ស |
| **៤-ការគ្រប់គ្រងព្រៃ លិចទឹក/កោងកាង** |
| ៤-១ ប្រជុំរៀបចំផែនការគ្រប់គ្រងព្រៃលិចទឹក/កោងកាង |
| ៤-២ ផ្សព្វផ្សាយអំពី ផែនការប្រើប្រាស់ព្រៃកោងកាង |
| ៤-៣ ប្រមូលគ្រាប់កោងកាង |
| ៤-៤ បណ្ដុះកូន ដាំ និងថែរក្សាការពារ |
| ៤-៥ កាប់រំលោះប្រើប្រាស់ក្នុងគ្រួសារ |
| **៥-ការចុះល្បាតទប់ស្កាត់បទល្មើស** |
| ៥-១ ទំនាក់ទំនងជាមួយស្ថាប័នពាក់ព័ន្ធនឹងការគ្រប់គ្រងសហគមន៍ |
| ៥-២ ផ្សព្វផ្សាយពីច្បាប់ជលផលថ្មីនិងច្បាប់បទដ្ឋាននានា |
| ៥-៣ ប្រជុំពិភាក្សាគណៈកម្មការសហគមន៍រៀបចំផែនការ |
| ៥-៤ ប្រជុំពិភាក្សាគណៈកម្មការសហគមន៍រៀបចំផែនការ |
| ៥-៥ សហការជាមួយស្ថាប័ន |

| | |
|---|---|
| ជំនាញសមត្ថកិច្ចមូលដ្ឋានក្នុងការចុះបង្ក្រាបបទល្មើស | |
| ៦-ផែនការថវិការទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ | |
| ៦-១ ភាគទានពីសមាជិកសហគមន៍នេសាទ | |
| ៦-២ ភាគទានប្រចាំឆ្នាំ | |

ភូមិលក ,ថ្ងៃទី ០3 ខែ ០2 ឆ្នាំ២០១៧
ប្រធានគណៈកម្មការសហគមន៍នេសាទលក

ឡាន-សាម៉ន

បានឃើញ
ឫស្សីស្រុកខាងលិច ,ថ្ងៃទី ០៣ ខែ ០២ ឆ្នាំ២០១៧
មេឃុំឫស្សីស្រុកខាងលិច

ចៅ-សាវី

បានឃើញនិងបញ្ជូនមក
លោកនាយខណ្ឌរដ្ឋបាលជលផលកំពត
កែប ,ថ្ងៃទី ០៦ ខែ ០២ ឆ្នាំ២០១៧
នាយផ្នែករដ្ឋបាលជលផលព្រែកចាក

ប៉ុក-នរិន្ទ

លេខ : ០៣០ ខរ.កព
បានឃើញនិងបញ្ជូនមក
លោកនាយអធិការដ្ឋានខណ្ឌរដ្ឋបាលជលផលសមុទ្រ
កំពត ,ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ២០១៧
នាយខណ្ឌរដ្ឋបាលជលផលកំពត

ស-សុរិន

លេខ : ០១៧ អ.រ.ស
បានឃើញនិងបញ្ជូនមក
ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជា
ប្រធានរដ្ឋបាលជលផល
"ដើម្បីពិនិត្យ និងសម្រេចដោយអនុគ្រោះ"
ព្រះសីហនុ ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ២០១៧
នាយអធិការដ្ឋានរដ្ឋបាលជលផលសមុទ្រ

ញ៉ឹ. ស៊ីត

លេខ : ៤៦៧ ជ.ន
បានឃើញ និងឯកភាព
រាជធានីភ្នំពេញ ,ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ២០១៧
**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជា**
**ប្រធានរដ្ឋបាលជលផល**

ណៅ-ធូក